**Office of Assistance Superintendent High Schools**
**1515 Hughes Way, Long Beach, CA 90810**
**Telephone: (562) 997-8000**

# សំណុំព័ត៌មានអំពីការជ្រើសរើសសាលាវិទ្យាល័យ

សំណុំពត៌មាននេះមានជាភាសាអង់គ្លេស អេស្ប៉ាញ៉ុល និងភាសាខ្មែរនៅតាមសាលារៀនទាំងអស់។

ខែវិច្ឆិកា ឆ្នាំ២០០៩

សូមជំរាបមកដល់មាតាបិតានៃសិស្សថ្នាក់ទី៨

ដែលជាផ្នែកមួយនៃផែនការធ្វើឲ្យមានជោគជ័យដល់ការសិក្សានិងអាជីព ក្រសួងអប់រំតំបន់ឡុងប៊ីចបានប្តេជ្ញាថានឹងរៀបបំរុងសិស្សានុសិស្សទាំងអស់សម្រាប់បន្តទៅសិក្សានៅសាលាសាកលវិទ្យាល័យហើយនិងពិភពនៃការងារ។ កម្មវិធីជ្រើសរើសសាលាវិទ្យាល័យគឺជាចំណែកមួយនៃការប្តេជ្ញានេះ។ នៅក្នុងខែធ្នូឆ្នាំ២០០៩នេះ លោកអ្នកនិងបុត្រធីតារបស់លោកអ្នកនឹងចាប់ផ្តើមធ្វើការជ្រើសរើសសាលាវិទ្យាល័យមួយសម្រាប់ទៅរៀននៅឆ្នាំក្រោយ ហើយព័ត៌មានខាងក្រោមនេះនឹងជួយលោកអ្នកក្នុងការជ្រើសរើស។

**សាលាវិទ្យាល័យសម្រាប់ជ្រើសរើស:** កម្មវិធីសិក្សាដែលមានផ្តល់ឲ្យនៅតាមសាលាវិទ្យាល័យទាំងប្រាំបីមានរាយរាប់ជាសង្ខេបនៅក្នុងសំណុំពត៌មាននេះ។ កម្មវិធីនិមួយៗមានសភាពផ្សេងៗពីគ្នាយោលទៅតាមការតម្រូវឲ្យមានក្នុងការទទួលយកសិស្ស ការឲ្យទម្ងន់ទៅលើកម្មវិធីសិក្សាចំនួននិងប្រភេទថ្នាក់ដែលសាលារៀនមាននិងសេចក្តីតម្រូវឲ្យមានផ្សេងៗ កំរឹតពិន្ទុ GPA ហើយនិងចរិយាមារយាទដែលត្រូវមានដើម្បីអាចនៅនៅរៀនក្នុងកម្មវិធី។ ដើម្បីឲ្យបានដឹងព័ត៌មានក្បោះក្បាយថែមទៀត សូមអញ្ជើញទៅចូលរួមក្នុងកម្មវិធីផ្តល់ព័ត៌មានខាងក្រោមនេះ:

- **ទិវាផ្តល់ពត៌មានអំពីសាលាវិទ្យាល័យ High School Choice Day: ថ្ងៃសៅរ៍ ទី៥ខែធ្នូនៅសាលាវិទ្យាល័យ Cabrillo H.S ពីម៉ោង៩:០០ព្រឹក-១២:០០ថ្ងៃត្រង់។** បុគ្គលិកពីសាលាវិទ្យាល័យនិមួយៗនឹងផ្តល់ជូនព័ត៌មានអំពីកម្មវិធីសិក្សាផ្សេងៗដូចជា ថ្នាក់រៀនដែលមានចំនួនសិស្សតិចគ្នា កម្មវិធីសម្រាប់សិស្សរៀនពូកែរ។ និងកម្មវិធីពិសេសផ្សេងៗទៀតជាដើម។

- **រាត្រីផ្តល់ពត៌មានអំពីសាលាវិទ្យាល័យ High School Parent-Student Information:** ពីថ្ងៃពុធទី២ខែធ្នូទៅដល់ថ្ងៃព្រហស្បតិ៍ទី១០ខែធ្នូឆ្នាំ២០០៩ សាលាវិទ្យាល័យទាំងឡាយនិងមានបើកកម្មវិធីផ្តល់ព័ត៌មានដល់មាតាបិតានិងការបង្ហាញឲ្យស្គាល់ថ្នាក់អប់រំពិសេស **SDC** នៅតាមសាលារៀន។ ខាងក្រោមនេះគឺជាតារាងវេលានៃកម្មវិធី:

**<u>កម្មវិធីផ្តល់ជូនព័ត៌មានទាំងអស់ខាងក្រោមនេះចាប់ផ្តើមនៅម៉ោង៦:០០ល្ងាច</u>**

| | |
|---|---|
| ថ្ងៃពុធទី២ធ្នូ - នៅសាលា **Renaissance** | ថ្ងៃអង្គារទី៨ធ្នូ - នៅសាលា **Millikan** |
| ថ្ងៃព្រហស្បតិ៍ទី៣ធ្នូ - នៅសាលា **Jordan** | ថ្ងៃពុធទី៩ធ្នូ - នៅសាលា **Lakewood** |
| ថ្ងៃព្រហស្បតិ៍ទី៣ធ្នូ - នៅសាលា **Wilson** | ថ្ងៃព្រហស្បតិ៍ទី១០ធ្នូ - នៅសាលា **Poly** |
| ថ្ងៃច័ន្ទទី៧ធ្នូ - នៅសាលា **Cabrillo** | |

**<u>ការណែនាំបង្ហាញឲ្យស្គាល់ថ្នាក់អប់រំពិសេស SDC ពេលព្រឹកនិងពេលរសៀល</u>**

ថ្ងៃព្រហស្បតិ៍ទី៣ធ្នូ - នៅសាលា **Jordan & Wilson**
ថ្ងៃច័ន្ទទី៧ធ្នូ - នៅសាលា **Cabrillo**
ថ្ងៃអង្គារទី៨ធ្នូ - នៅសាលា **Millikan & Poly**
ថ្ងៃព្រហស្បតិ៍ទី១០ធ្នូ - នៅសាលា **Lakewood**

ដើម្បីព័ត៌មានថែមទៀតនិងព័ត៌មានជាភាសាខ្មែរ សូមចូលទៅវែបសាយរបស់ក្រសួងអប់រំនៅ www.lbschools.net ។ មុននឹងជ្រើសរើសយកសាលាណាមួយ សូមពិភាក្សាជាមួយអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សាឬអ្នកធ្វើការទំនាក់ទំនងមាតាបិតាជាមុនសិន។

**របៀបដាក់សំណុំពាក្យ:** សិស្សថ្នាក់ទី៨ទាំងអស់នៅក្នុងក្រសួងអប់រំឡុងប៊ិច LBUSD ត្រូវបំពេញហើយដាក់សំណុំពាក្យ *High School /Secondary Specialized Programs* ។ គំរូក្រដាសពាក្យមួយច្បាប់មានដាក់នៅក្នុងសំណុំព័ត៌មាននេះ។ ក្រដាសពាក្យសុំនេះនឹងមាននៅសាលាមធ្យមសិក្សាចាប់ពីថ្ងៃទី១៦ខែវិច្ឆិកាតទៅ។ បើសិនជាលោកអ្នកត្រូវការជំនួយក្នុងការបំពេញក្រដាសពាក្យសុំនេះ សូមទាក់ទងអ្នកផ្តល់ឱវាទឬអ្នកទំនាក់ទំនងមាតាបិតានៅសាលាមធ្យមសិក្សារបស់បុត្រធីតាលោកអ្នក។

ក្រដាសពាក្យសុំដែលបានបំពេញរួចត្រូវយកទៅប្រគល់ឲ្យអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សាឲ្យបានទាន់ថ្ងៃកំណត់របស់សាលានោះ។ ចំពោះសាលាមធ្យមសិក្សាភាគច្រើន ថ្ងៃផុតកំណត់របស់គេគឺថ្ងៃទី១៨ខែធ្នូ ឆ្នាំ២០០៩។ ចំណែកឯសាលាមធ្យមសិក្សា Butler, Powell និង Robinson, ថ្ងៃផុតកំណត់របស់គេគឺថ្ងៃទី៨ខែមករា ឆ្នាំ២០១០។ សូមអានប្រក្រតិទិនដែលភ្ជាប់មកជាមួយនេះដើម្បីឲ្យដឹងថ្ងៃកំណត់ក្បោះក្បាយ។

**សិស្សនៅសាលាឯកជន** អាចទៅយកក្រដាសពាក្យសុំនេះនៅការិយាល័យសាលារបស់គេ ឬនៅការិយាល័យ School of Choice ដែលស្ថិតនៅលេខ 3701 E. Willow St., L.B។ សូមទូរស័ព្ទលេខ 562-426-6846 ext. 276 បើត្រូវការការប្រាប់បង្ហាញផ្លូវ។ សិស្សនៅសាលាឯកជនត្រូវដាក់ពាក្យសុំនេះផ្ទាល់តែម្តងនៅសាលាវិទ្យាល័យ High School/Secondary Specialized Program ។

សូមជ្រាបថា ដោយសារកន្លែងមានកំរិតហើយនិងតម្រូវការច្បាស់លាស់ផ្សេងៗ សាលារៀនជំរើសទីមួយរបស់អ្នកប្រហែលជាមិនអាចទទួលយកពាក្យសុំរបស់លោកអ្នកបានទេ។ ថែមពីនោះទៀត ពាក្យសុំដែលដាក់មិនទាន់ពេលកំណត់នឹងត្រូវ យកមកគិតពិចារណាលុះណាទាល់តែសំណុំពាក្យទាំងអស់ដែលបានដាក់ទាន់ថ្ងៃកំណត់បានត្រូវគេពិនិត្យគិតគូររួចអស់ហើយ ហើយបើសាលាវិទ្យាល័យដែលសិស្សសុំចូលទៅរៀននោះមាននៅសល់កន្លែង។

**ការដាក់សិស្សឲ្យរៀននៅសាលាវិទ្យាល័យ:** សិស្សនឹងដាក់ឲ្យរៀននៅសាលាវិទ្យាល័យនានាដោយអនុវត្តតាមទម្រង់ការចុះឈ្មោះតាមអាទិភាពគឺសិទ្ធិដែលត្រូវបានទទួលឲ្យចូលរៀនបានមុនគេយោលទៅតាមគោលការណ៏ណែនាំដែលបានបង្កើតឡើងនៅក្នុងសៀវភៅមគ្គុទេសក៏ *Student Enrollment Options Handbook* ហើយនិងសៀវភៅ *LBUSD K-12 Guidelines for Students and Parents* ។ ជាសង្ខេប អាទិភាពទីមួយគឺផ្តល់ឲ្យសិស្សដែលរស់នៅក្នុងតំបន់សាលារៀនហើយនិងសិស្សដែលសាលារៀននៅក្នុងតំបន់ពេញចំណុះសិស្សអស់ហើយ។ អាទិភាពទីពីរគឺផ្តល់ឲ្យសិស្សដែលទទួលឲ្យចូលក្នុងកម្មវិធីពិសេស Secondary Specialized Program ។ អាទិភាពទីបីគឺផ្តល់ឲ្យសិស្សតាមការ ជ្រើសរើសចាប់ឆ្នោះដោយព្រាវ។

ការជូនដំណឹងអំពីការទទួល ឬ ការបដិសេធឲ្យចូលរៀននៅសាលាវិទ្យាល័យក្នុងកម្មវិធី Secondary Specialized Program ដែលសម្រេចឡើងយោងតាមពត៏មាននៅលើក្រដាសដាក់ពាក្យសុំនោះនឹងត្រូវផ្ញើទៅផ្ទះសិស្សដោយការិយាល័យប្រចាំសាលាសាលាវិទ្យាល័យមុនថ្ងៃទី២៩ខែមករា។ សិស្សណាដែលមិនបានទទួលឲ្យចូលក្នុងកម្មវិធី Secondary Specialized Program នឹងត្រូវដាក់ឲ្យរៀននៅសាលាវិទ្យាល័យក្នុងតំបន់លំនៅស្ថានឬនៅសាលាណាមួយទៀត ហើយនឹងត្រូវផ្តល់ដំណឹងនេះតាមរយៈសំបុត្រប៉ុស្តនៅដើមខែមិនា។

អ្នកផ្តល់ឱវាទនៅសាលាវិទ្យាល័យនឹងទៅសាលាមធ្យមសិក្សានៅក្នុងខែមិនាដើម្បីរៀបចំចាត់ចែងសិស្សថ្នាក់ទី៨សម្រាប់សាលាវិទ្យាល័យ។

**សិស្សក្នុងកម្មវិធីពិសេស SDC:** បើសិនជាលោកអ្នកមានបុត្រធីតារៀននៅក្នុងកម្មវិធីអប់រំពិសេស “Special Day Class” (SDC) លោកអ្នកនឹងបានទទួលសំបុត្រមួយច្បាប់នៅក្នុងខែវិច្ឆិកាពីការិយាល័យនៃការអប់រំពិសេសដែលនឹងមានជំរាបអំពីសាលារៀនមួយណាសម្រាប់បុត្រធីតាលោកអ្នកទៅរៀននៅឆ្នាំក្រោយ ព្រមទាំងពត៏មានពីទម្រង់ការក្នុងការជ្រើសរើសសាលាផងដែរ។ ក្រដាសដាក់ពាក្យសុំដូរសាលាពណ៌ខៀវ *School of Choice* សម្រាប់សិស្ស SDC មាននៅការីយាល័យនៃការអប់រំពិសេស។ សិស្សដែលទទួលជំនួយ សេវាអប់រំពិសេស Resource Specialist Program (RSP) សូមធ្វើតាមលំនាំនៃការដាក់ពាក្យសំណុំពាក្យសុំចូលសាលាវិទ្យាល័យ។

បើលោកអ្នកមានសំនួរអ្វីមួយ សូមកុំរួញរានឹងទូរស័ព្ទទៅការិយាល័យសាលាវិទ្យាល័យនៅលេខ(៥៦២) ៩៩៧-៨១១៣ ការិយាល័យកម្មវិធី Magnet នៅលេខ (៥៦២)៩៩៧-៨៣០៨ ឬការិយាល័យចាត់ដាក់ឲ្យសិស្សរៀននៅលេខ (៥៦២)៤២៦-៦៨៤៦ ext. ២៧៩។

ដោយសេចក្តីស្មោះចំពោះ

Sally Gregory
អភិបាលកម្មវិធី

អនុញ្ញាតឲ្យបោះពុម្ពផ្សាយ:

Maggie Webster
អនុអគ្គនាយកប្រចាំសាលាវិទ្យាល័យ

CHOICE FLYER

# រាត្រីពត៌មានសម្រាប់សិស្សនិងមាតាបិតា

ដើម្បីឲ្យបានដឹងថែមអំពីកម្មវិធីទូទៅដែលមានផ្តល់ឲ្យនៅតាមសាលាវិទ្យាល័យទាំងឡាយ ដូចជាថ្នាក់ Honors និង Advanced Placement ថ្នាក់ដែលអាចជ្រើសរើសតាមចំណូលចិត្ត (visual និង performing arts, អត្តពលកម្ម ភ្លេង cheer, color guard, JROTC ជាដើម), មណ្ឌលអាជីព ហើយនិងសេវាដ៏ទៃៗទៀត សូមអញ្ជើញទៅចូលរួមក្នុងកម្មវិធីជូនពត៌មានមាតាបិតានៅតាមសាលារៀននោះ។

| សាលា/ទីកន្លែង<br>អាស័យដ្ឋាន ទូរស័ព | ថ្ងៃខែ | ម៉ោង |
|---|---|---|
| **Renaissance**— សវ៉ៃនដ្ឋាន<br>235 East Eighth Street, LB<br>562-901-0168 | ថ្ងៃពុធ ទី២ខែធ្នូ | ៦:០០ ល្ងាច |
| **Jordan Main Campus**<br>6500 Atlantic Avenue, LB<br>562-423-1471 | ថ្ងៃព្រហស្បតិ៍ ទី៣ខែធ្នូ | ៦:០០ ល្ងាច |
| **Wilson**— សវ៉ៃនដ្ឋាន<br>4400 East Tenth Street, LB<br>562-433-0481 | ថ្ងៃព្រហស្បតិ៍ ទី៣ខែធ្នូ | ៦:៣០ ល្ងាច |
| **Cabrillo**—សវ៉ៃនដ្ឋាន<br>2001 Santa Fe Avenue, LB<br>562-951-7700 | ថ្ងៃច័ន្ទ ទី៧ខែធ្នូ | ៦:៣០ ល្ងាច |
| **Millikan—** សវ៉ៃនដ្ឋាន<br>2800 Snowden Avenue, LB<br>562-425-7441 | ថ្ងៃព្រហស្បតិ៍ ទី៨ខែធ្នូ | ៦:៣០ ល្ងាច |
| **Lakewood**— សវ៉ៃនដ្ឋាន<br>4400 Briercrest Avenue, Lakewood<br>562-425-1281 | ថ្ងៃពុធ ទី៩ខែធ្នូ | ៦:៣០ ល្ងាច |
| **Poly**— សវ៉ៃនដ្ឋាន<br>1600 Atlantic Avenue, LB<br>562-591-0581 | ថ្ងៃព្រហស្បតិ៍ ទី១០ខែធ្នូ | ៦:៣០ ល្ងាច |

## ថ្ងៃខែសំខាន់ៗដែលត្រូវចងចាំ

### ថ្ងៃច័ន្ទ ទី១៦ ខែវិច្ឆិកា
ក្រដាសពាក្យសុំចូលរៀនសាលាវិទ្យាល័យ *High School/ Secondary Specialized Program* ចាប់ផ្តើមសុំបានពីអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សា។

### ថ្ងៃសៅរ៏ទី៥ ខែធ្នូ
**កម្មវិធីទិវាផ្តល់ពត៌មានអំពីសាលាវិទ្យាល័យ**
**High School Choice Information Day**
នៅសាលាវិទ្យាល័យ Cabrillo ពីម៉ោង៩:០០ព្រឹកទៅ១២:០០ថ្ងៃ។ មកទទួលពត៌មានអំពីកម្មវិធីសិក្សាផ្សេងៗនៅសាលាវិទ្យាល័យទាំងអស់ ដូចជាថ្នាក់រៀនដែលមានចំនួនសិស្សតិច កម្មវិធីសម្រាប់សិស្សរៀនពូកែនិងកម្មវិធីពិសេសផ្សេងៗទៀត។

### ពីថ្ងៃទី២-ទី១០ខែធ្នូ
**រាត្រីពត៌មានសម្រាប់សិស្សនិងមាតាបិតាសិស្សថ្នាក់ទី៨**
នៅតាមទីកន្លែងនិងថ្ងៃខែខុសៗគ្នា។

### ថ្ងៃសុក្រទី១៨ខែធ្នូ**
**ថ្ងៃផុតកំណុតសម្រាប់សិស្សដាក់ប្រគល់ក្រដាសពាក្យសុំ *Application for High School/ Secondary Specialized Programs* ទៅឲ្យអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សាវិញ។**
** នាយកសាលាឬអ្នកផ្តល់ឱវាទរបស់បុត្រធីតាលោកអ្នកប្រហែលតម្រូវឲ្យដាក់សំណុំពាក្យនេះឲ្យទាន់ថ្ងៃកំណត់ដែលមុនថ្ងៃទី១៨នេះ។

សិស្សសាលាឯកជនដាក់ពាក្យសុំនេះទៅឲ្យអ្នកផ្តល់ឱវាទនៅសាលាឯកជននោះឬយកទៅឲ្យនៅសាលាវិទ្យាល័យផ្ទាល់តែម្តងក៏បាន។

*ថ្ងៃកំណត់សាលា* ***Robinson, Butler*** *និង* ***Powell*** *គឺថ្ងៃទី៨មករា២០១០*

ថ្ងៃសុក្រទី២៩មករា សំបុត្របញ្ជាក់ប្រាប់ពីការទទួលយកឬមិនទទួលយកឲ្យចូល កម្មវិធី **Secondary/Specialized Program** នឹងផ្ញើទៅផ្ទះ។

### ថ្ងៃទី១២កុម្ភះ
**ថ្ងៃផុតកំណត់សម្រាប់សិស្សដែលបានទទួលឲ្យចូលកម្មវិធីពិសេស Secondary/ Specialized Program យកក្រដាសបញ្ជាក់ *Intent to Attend* ទៅឲ្យអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សាវិញ។**

សិស្សសាលាឯកជនដាក់ពាក្យសុំនេះទៅឲ្យសាលាវិទ្យាល័យផ្ទាល់។

**ដើមខែមិនា: សំបុត្រប្រាប់ថាសិស្សត្រូវទៅរៀននៅសាលាវិទ្យាល័យមួយណានឹងផ្ញើទៅផ្ទះ។**

## ការនាំជូនទស្សនាកម្មវិធីអប់រំពិសេស

ថ្ងៃព្រហស្បតិ៍ ទី៣ខែធ្នូ សាលាJordan & Wilson
ថ្ងៃច័ន្ទ ទី៧ខែធ្នូ សាលាCabrillo
ថ្ងៃអង្គារ ទី៨ខែធ្នូ សាលាMillikan & Poly
ថ្ងៃព្រហស្បតិ៍ ទី១០ខែធ្នូ សាលាLakewood

## ថ្ងៃខែប្រក្រតិទិនសម្រាប់ក្រសួងអប់រំទាំងមូល

| | |
|---|---|
| ថ្ងៃច័ន្ទទី១៨មករា | បុណ្យ Martin Luther King Jr. (សាលាបិទទ្វារ) |
| ថ្ងៃច័ន្ទទី៨កុម្ភះ | បុណ្យ Lincoln (សិស្សឈប់សម្រាក) |
| ថ្ងៃច័ន្ទទី១៥កុម្ភះ | បុណ្យ Washington (សិស្សឈប់សម្រាក) |
| ថ្ងៃអង្គារទី២៣មិនា | កម្មវិធី Open House សាលាមធ្យមសិក្សា |
| ថ្ងៃពុធទី២៤មិនា | កម្មវិធី Open House សាលាវិទ្យាល័យ |
| ថ្ងៃទី៥-ទី១៥មេសា | វ៉ាកងតូចនិទាឃរដូវ Spring Recess (សិស្សឈប់សម្រាក) |
| ថ្ងៃច័ន្ទទី៣១ឧសភា | បុណ្យ Memorial (សិស្សឈប់សម្រាក) |

**ពាក្យសុំចូលកម្មវិធីពិសេសនៅវិទ្យាល័យ High School /Secondary Specialized Program ជាគំរូប័ណ្ណុះ**

បំពេញហើយយកពាក្យសុំនេះទៅឲ្យអ្នកផ្តល់ឱវាទសាលាមធ្យមសិក្សាវិញឲ្យបានទាន់ថ្ងៃសុក្រទី**១៨ខែធ្នូឆ្នាំ២០០៩**។

កត់សំគាល់: នាយកសាលានិងអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សាអ្នកអាចតម្រូវឲ្យយកពាក្យសុំនេះមកឲ្យសាលាមុនថ្ងៃកំណត់ខាងលើនេះ។

# ក្រដាសពាក្យសុំនេះគ្រាន់តែជាគំរូប័ណ្ណុះ

នាមត្រកូលសិស្ស ____ នាមខ្លួន ____ ថ្ងៃកំណើត(ខែ/ថ្ងៃ/ឆ្នាំ) ____ សាលាវិទ្យាល័យក្នុងតំបន់ទីលំនៅ ____

អាស័យដ្ឋាន ____ លេខបន្ទប់ # ____ ទីក្រុង ____ លេខប្រៃសណីយប្រចាំតំបន់ ____

លេខទូរស័ព្ទផ្ទះ ____ លេខទូរស័ព្ទកន្លែងធ្វើការ ____ លេខអាស័យដ្ឋានអីមែល ____ សាលាមធ្យមសិក្សាបច្ចុប្បន្ន ____

**ទម្រង់ការដាក់ពាក្យ:** សិស្សថ្នាក់ទី៨នៅក្នុងក្រសួងអប់រំឡុងបិចLBUSD ទាំងអស់ត្រូវបំពេញក្រដាសពាក្យសុំនេះហើយយកទៅឲ្យអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សាវិញឲ្យបានទាន់ថ្ងៃផុតកំណត់ទី១៨ខែធ្នូ។

**ជំហានទី១:** គូសរង្វង់លើសាលារៀនខាងក្រោមនេះដែលនៅក្នុងតំបន់លំនៅដ្ឋានអ្នក ហើយរើសយកកម្មវិធីពិសេស Small Learning Communities នៅសាលានោះដោយសរសេរលេខ “1”, “2” និង “3” លើបន្ទាត់ខាងនុខកម្មវិធីពិសេសនោះ។

**ជំហានទី២:** រើសសាលាវិទ្យាល័យ២ណាដែលអ្នកចង់ដាក់ពាក្យសុំចូលដោយសរសេរលេខ “1” និង “2” នៅពីក្រោមសាលាជម្រើសរបស់អ្នក។

**ជំហានទី៣:** រើសយកកម្មវិធីពិសេស Small Learning Communities ដោយសរសេរលេខ “1”, “2” និង “3” សំរាប់ជំរើសទី១ ទី២ និងទី៣ សម្រាប់សាលាវិទ្យាល័យទាំង២នេះ។

| **CABRILLO** ____ | **JORDAN** ____ | **LAKEWOOD** ____ | **MILLIKAN** [1] ____ | **POLY** ____ | **WILSON** [1] ____ |
|---|---|---|---|---|---|
| ___CHOC Academy<br>___CALJ Academy<br>___ISC Academy<br>___CAB | ___BESTT<br>___ETA<br>___JMAC<br>___JLS<br>___JTECH<br>___Panther International | ___TCB Academy<br>___HERO Academy<br>___Odyssey Academy<br>___The Arts SLC | ___Global Tech<br>___MBA<br>___STELLAR<br>___GREEN | ___ Humanities Academy<br>___Beach<br>___MAPS Academy<br>___METS Academy | ___Wilson Classical High School |

[1] ការព្រមព្រៀងទៅលើឯកសណ្ឋាននឹងចរិយាមារយាទក៏តម្រូវឲ្យមានដែរនៅសាលានេះ។

**ជំហានទី៤:** បើអ្នកមានចំណាប់អារម្មណ៏លើកម្មវិធីពិសេសខាងក្រោមនេះ((មិនបាច់ក៏បាន) រើសយក**កម្មវិធីពិសេសបីមុខ**ដោយសរសេរលេខ “1”, “2” និង “3” សំរាប់ជំរើសទី១ ទី២ និងទី៣។ <u>កម្មវិធពិសេសទាំងនេះមានតម្រូវការតឹងរឹងថែមទៀតក្នុងការទទួលយក។</u>

ACE (Jordan)
AIMS (Jordan)
ATM (Lakewood)
CED (Cabrillo)
CIC[2] (Poly)
COMPASS[1] (Millikan)

Distinguished Scholars[1] (Wilson)
IB** (Jordan)
Merit Scholars (Lakewood)
PACE (Poly)
PAC RIM** (Poly)
PEACE[1] (Millikan)

QUEST[1] (Millikan)
SACMAA (Cabrillo)
University Scholars (Cabrillo)

**<u>សាលានេះជាសាលាពិសេស Specialized Program</u>**

CAMS[2] (ក្រដាសពាក្យសុំត្រូវឲ្យទៅសាលា CAMS ឲ្យទាន់ថ្ងៃទី១៨ធ្នូ)
Renaissance

[1] ការព្រមព្រៀងទៅលើឯកសណ្ឋាននឹងចរិយាមារយាទក៏តម្រូវឲ្យមានដែរនៅសាលានេះ

[2] ក្រដាសពាក្យសុំមួយសន្លឹកទៀត “supplemental application” ក៏ត្រូវការបន្ថែមសម្រាប់សាលា CAMS និងសាលា CIC។ យកពាក្យសុំបន្ថែមនេះពីអ្នកផ្តល់ឱវាទ។

**កម្មវិធីពិសេស Magnet ដែលផ្គត់ផ្គង់ថវិការដោយសហព័ន្ធ** (International Baccalaureate & PAC RIM)

បើអ្នកកំពុងរៀនក្នុងកម្មវិធី Magnet/Gifted/GATE សូមសរសេរប្រាប់កម្មវិធីមួយណានៅលើបន្ទាត់នេះ:________________________________.

**កម្មវិធីសិក្សាដែលសិស្សអាចជ្រើសរើសបានតាមចំណូលចិត្ត: (Elective Programs)**

**AVID** (**A**dvancement **V**ia **I**ndividual **D**etermination) មានផ្តល់ឲ្យនៅតាមសាលាវិទ្យាល័យទាំងអស់។ ថ្នាក់រើសយកតាមចំណូលចិត្តទាំងនេះផ្តល់ឲ្យសិស្សនូវជំនាញសិក្សាសំខាន់ៗដែលចាំបាច់សម្រាប់រៀនឲ្យបានជោគជ័យ។ សូមគូសរើសតាមចំណុចខាងក្រោមដែលសមរម្យចំពោះអ្នក:

___ សព្វថ្ងៃខ្ញុំកំពុងរៀនក្នុងកម្មវិធី AVID ក្នុងថ្នាក់ទី៨ហើយចង់រៀនក្នុងកម្មវិធីនេះបន្តទៅទៀតនៅសាលាវិទ្យាល័យ។
___ ខ្ញុំមិនបានរៀនក្នុងកម្មវិធី AVID ទេ ក៏ប៉ុន្តែខ្ញុំចង់បានព័ត៌មានបន្ថែមទៀតអំពីកម្មវិធីនេះ។
___ ខ្ញុំមិនមានចំណាប់អារម្មណ៍ក្នុងកម្មវិធី AVID ទេ។

**ការដឹកជូនដំណើរតាមឡានបឺសសាលា:** ការដឹកជូនដំណើរតាមឡានបឺសនិង**មិន**មានផ្តល់ឲ្យសិស្សដែលទទួលឲ្យរៀននៅសាលាដែលសិស្សជ្រើសរើសឬ សិស្សនៅក្នុងកម្មវិធី Magnet ឬនៅក្នុងកម្មវិធីពិសេសទេ។

សិស្សដែលបានដាក់ពាក្យសុំចូលកម្មវិធីពិសេស **Secondary Specialized Program** នឹងបានទទួលតាមរយៈសំបុត្រប៉ុស្តនូវដំណឹងអំពីស្ថានភាពនៃពាក្យសុំនៅក្នុងសប្តាហ៏ទី១នៃខែកុម្ភៈឆ្នាំ២០១០ ព្រមទាំងសំបុត្របញ្ជាក់“បំរុងនឹងទៅរៀន” **“Intend to Attend”** ចំពោះសិស្សណាដែលបានទទួលឲ្យចូលកម្មវិធី។ សិស្សណាដែលបានទទួលឲ្យចូលកម្មវិធីពិសេសត្រូវតែយកក្រដាស **“Intend to Attend”** ទៅឲ្យអ្នកផ្តល់ឱវាទនៅសាលាមធ្យមសិក្សាវិញឲ្យទាន់ថ្ងៃទី១២ខែកុម្ភៈ២០១០ ហើយនៅពេលនោះសិស្សនឹងបានបំពេញរួចរាល់អស់ហើយនូវការដាក់ពាក្យសុំសំរាប់សិស្សដែលសំរេចចូលក្នុងកម្មវិធីពិសេស។
**បន្ទាប់ពីថ្ងៃទី១៩ខែកុម្ភៈឆ្នាំ២០១០ទៅ សិស្សពុំអាចធ្វើការផ្លាស់ប្តូរបានទេ។**

សិស្សណាដែល**មិន**បានរៀនក្នុងកម្មវិធីពិសេស **Secondary Specialized Program** នឹងត្រូវចាត់ដាក់ឲ្យទៅរៀននៅសាលាវិទ្យាល័យណាមួយមិនឲ្យហួសពីសប្តាហ៏ទី១នៃខែមិនាឡើយហើយសិស្សនោះនឹងបានទទួលតាមរយៈសំបុត្រប៉ុស្ត នូវឈ្មោះសាលាវិទ្យាល័យដែលសិស្សនឹងទៅរៀន។ នៅក្នុងខែមិនា អ្នកផ្តល់ឱវាទនៅសាលវិទ្យាល័យនឹងរៀបចំចាត់ចែងសិស្សថ្នាក់ទី៨ទាំងអស់សម្រាប់ទៅរៀននៅសាលាវិទ្យាល័យក្នុងឆ្នាំសិក្សា២០១០-២០១១។

**សូមអរគុណដល់ការចូលរួមក្នុងដំណើរការជ្រើសរើសសាលាវិទ្យាល័យ! ការខិតខំទាំងអស់ត្រូវបានធ្វើឡើងដើម្បីធ្វើយ៉ាងណាដើម្បីឲ្យសិស្សបានទៅរៀននៅសាលាជំរើសទីមួយរបស់គេ ដែលអាទិភាពនឹងផ្តល់ឲ្យសិស្សដែលមានទីលំនៅនៅក្នុងតំបន់សាលារៀននោះ។**

X________________________ X________________________ ________________
ហត្ថលេខាសិស្ស ហត្ថលេខាមាតាបិតាឬអ្នកថែរក្សាសិស្ស ថ្ងៃខែ

**សំរាប់ការិយាល័យប័ណ្ណះ FOR OFFICE USE ONLY**

Comments:______________________________________________________________

X________________________________ ____________________ ________________________
Counselor Signature Date Middle School